**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ធនាគារជាតិនៃកម្ពុជា**

លេខ.....................................................

*ថ្ងៃព្រហស្បតិ៍ ១២កើត ខែអស្សុជ ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣*
*រាជធានីភ្នំពេញ ថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៩*

## សេចក្តីប្រកាសព័ត៌មាន
## ស្តីពី
## ពិធីប្រារព្ធខួបអនុស្សាវរីយ៍លើកទី ៤០ នៃការបង្កើតធនាគារជាតិនៃកម្ពុជាឡើងវិញ
## "១០ តុលា ១៩៧៩ - ១០ តុលា ២០១៩"

នៅថ្ងៃព្រហស្បតិ៍ ១២កើត ខែអស្សុជ ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣ ត្រូវនឹងថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៩ ធនាគារជាតិនៃកម្ពុជាបានប្រារព្ធពិធីរំលឹកខួបអនុស្សាវរីយ៍លើកទី ៤០ នៃការបង្កើតធនាគារជាតិនៃកម្ពុជាឡើងវិញ "១០ តុលា ១៩៧៩ - ១០ តុលា ២០១៩" នៅសាលសន្និសីទចតុមុខ ក្រោមអធីបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**។ ក្នុងឱកាសនេះក៏មានការអញ្ជើញចូលរួមរបស់សមាជិក សមាជិកា រដ្ឋសភា ព្រឹទ្ធសភា និងរាជរដ្ឋាភិបាល ថ្នាក់ដឹកនាំគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ អង្គទូត តំណាងអង្គការជាតិ និងអន្តរជាតិ ថ្នាក់ដឹកនាំនិងមន្ត្រីបុគ្គលិកធនាគារជាតិនៃកម្ពុជា សរុបប្រមាណ ៦០០នាក់។

**សម្តេចតេជោនាយករដ្ឋមន្ត្រី** បានអបអរសាទរនិងវាយតម្លៃខ្ពស់ ចំពោះធនាគារជាតិនៃកម្ពុជា ក៏ដូចជាប្រព័ន្ធធនាគារទាំងមូល ដែលសម្រេចបានសមិទ្ធផលយ៉ាងឆាប់រហ័ស គួរជាទីពេញចិត្ត។ **សម្តេចតេជោ** បានបញ្ជាក់ពីតួនាទីដ៏សំខាន់របស់ធនាគារកណ្តាល និងរូបិយវត្ថុជាតិ នៅក្នុងប្រវត្តិសាស្ត្រកម្ពុជា ដែលពង្រឹងនូវអធិបតេយ្យភាពជាតិ និងអំណាចរបស់រដ្ឋ។ រយៈពេល ៤០ឆ្នាំចុងក្រោយ គឺជាប្រវត្តិសាស្ត្រមួយ ដែលកម្ពុជារក្សាបាននូវនិរន្តរភាពនៃវត្តមានធនាគារកណ្តាលនិងប្រាក់រៀល។ ធនាគារជាតិនៃកម្ពុជា និងប្រព័ន្ធធនាគារ បានរីកចម្រើនគួរឱ្យកត់សម្គាល់ ទាំងផ្នែករូបវន្ត ហិរញ្ញវត្ថុ និងធនធានមនុស្ស ហើយបានចូលរួមចំណែកយ៉ាងសកម្មក្នុងការរក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច អភិវឌ្ឍសេដ្ឋកិច្ច និងកាត់បន្ថយភាពក្រីក្រនៅកម្ពុជា។ ជាក់ស្តែង ប្រាក់រៀលត្រូវបានរក្សាឱ្យមានស្ថិរភាពយ៉ាងល្អប្រសើរ ដោយបានប្រែប្រួលក្នុងរង្វង់តែ ១% ប៉ុណ្ណោះ ហើយទុនបម្រុងអន្តរជាតិត្រូវបានគរពូនឱ្យស្ថិតក្នុងកម្រិតខ្ពស់រហូតដល់ ១៥,៥ ប៊ីលានដុល្លារអាមេរិក ស្របពេលដែលអតិផរណាមានកម្រិតទាបប្រមាណ ៣%។ បច្ចុប្បន្ន ប្រជាជនពេញវ័យប្រមាណ ៧១% កំពុងទទួលបានសេវាហិរញ្ញវត្ថុ ហើយការផ្តល់ឥណទានតាមរយៈប្រព័ន្ធធនាគារបានកើនឡើងដល់ ១១៥% នៃផ.ស.ស. សម្រាប់បំពេញសេចក្តីត្រូវការពង្រីកអាជីវកម្មលើគ្រប់វិស័យ។ ទន្ទឹមនេះ ហេដ្ឋារចនាសម្ព័ន្ធហិរញ្ញវត្ថុ ជាពិសេសប្រព័ន្ធទូទាត់សងប្រាក់ ក៏ត្រូវបានធ្វើទំនើបកម្មជាលំដាប់ ដោយបានកាត់បន្ថយចំណាយប្រតិបត្តិការ ពង្រឹងប្រសិទ្ធភាព និងសុវត្ថិភាពនៃការទូទាត់។ **សម្តេចតេជោនាយករដ្ឋមន្ត្រី** ក៏បានផ្តល់អនុសាសន៍មួយចំនួនដល់ធនាគារជាតិនៃកម្ពុជានិងភាគីពាក់ព័ន្ធ ដើម្បីសម្រេចបានសមិទ្ធផលថ្មីៗបន្ថែមទៀត នាពេលខាងមុខ រួមមាន៖ ទី១/-ការបន្តរក្សាស្ថិរភាព និងពង្រឹងជំនឿទុកចិត្តលើរូបិយវត្ថុជាតិ ដើម្បីលើកកម្ពស់អត្តសញ្ញាណនិងអធិបតេយ្យភាព



ប្រអប់សំបុត្រលេខ ២៥, ឡូត៍លេខ ៤៨ ផ្លូវលេខ ១០២ កែងនឹងផ្លូវលេខ ១៩ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ , ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ / ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧

ជាតិ ទី២/-ការបន្តអភិវឌ្ឍវិស័យធនាគារប្រកបដោយភាពរឹងមាំនិងបរិយាប័ន្ន ដើម្បីបន្តលើកកម្ពស់បរិយាប័ន្នហិរញ្ញវត្ថុ និងលើកស្ទួយជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ទី៣/-ត្រូវបន្តគាំទ្រការប្រើប្រាស់បច្ចេកវិទ្យាថ្មីៗ និងត្រូវធ្វើការត្រួតពិនិត្យអំពីហានិភ័យនៃបច្ចេកវិទ្យាថ្មីៗទាំងអស់នេះ ដើម្បីរក្សាបាននូវស្ថិរភាព និងការអភិវឌ្ឍវិស័យហិរញ្ញវត្ថុនៅកម្ពុជា ទី៤/-ត្រូវបន្តលើកកម្ពស់ការយល់ដឹងផ្នែកហិរញ្ញវត្ថុដល់ប្រជាជន, ត្រូវបន្តចូលរួមបង្កើនការយល់ដឹង និងពង្រឹងវប្បធម៌ឥណទានដល់អ្នកដែលកំពុងប្រើប្រាស់សេវាហិរញ្ញវត្ថុ ជាពិសេសនៅតាមជនបទ ដើម្បីទប់ស្កាត់នូវហានិភ័យនានា ដែលអាចកើតឡើងជាយថាហេតុ នាពេលបច្ចុប្បន្ន និងអនាគត និង ទី៥/-ត្រូវបន្តពង្រឹងការទប់ស្កាត់ឱ្យបានទាន់ពេលវេលាប្រកបដោយប្រសិទ្ធភាពនូវការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ដើម្បីការពារវិស័យធនាគារនិងហិរញ្ញវត្ថុ ប្រកបដោយតម្លាភាព និងអភិបាលកិច្ចល្អ ។

ឯកឧត្តម ជា ចាន់តូ ទេសាភិបាលធនាគារជាតិនៃកម្ពុជា ក៏បានរាយការណ៍ជូន **សម្តេចតេជោនាយករដ្ឋមន្ត្រី** និងអង្គពិធី អំពីការវិវត្តរីកចម្រើនរបស់ធនាគារជាតិនៃកម្ពុជា ក្នុងរយៈពេល ៤០ឆ្នាំកន្លងមក ក្រោយពីថ្ងៃមហាជ័យជម្នះ ៧ មករា ១៩៧៩។ ប្រព័ន្ធធនាគារត្រូវបានស្តារចេញពីចំណុចសូន្យ និងបានឆ្លងកាត់នូវដំណាក់កាលអភិវឌ្ឍន៍ជាច្រើនដោយជោគជ័យ ហើយមកទល់បច្ចុប្បន្ន ធនាគារជាតិនៃកម្ពុជាបានពង្រឹងខ្លួនជាលំដាប់ ជាមួយនឹងសាខារាជធានី-ខេត្តចំនួន ១៩ នៅទូទាំងប្រទេស ដើម្បីធានាឱ្យបាននូវប្រព័ន្ធរូបិយវត្ថុនិងធនាគារប្រកបដោយប្រសិទ្ធភាពនិងទំនុកចិត្ត។ ទន្ទឹមនេះ វិស័យធនាគារបានអភិវឌ្ឍយ៉ាងឆាប់រហ័ស ជាពិសេសក្នុងរយៈពេល ២ទសវត្សរ៍ចុងក្រោយនេះ ដោយទ្រព្យសកម្មសរុបបានកើនឡើងគួរឱ្យកត់សម្គាល់ ពីប្រមាណត្រឹមតែ ១,៧ ទ្រីលានរៀល (ស្មើនឹងប្រមាណ ០,៥ ប៊ីលានដុល្លារអាមេរិក) ដល់ ១៨៩ ទ្រីលានរៀល (ប្រមាណ ៤៧ ប៊ីលានដុល្លារអាមេរិក) គឺកើនឡើង ១០៩ដង។ ចំនួនគណនីឥណទាន និងប្រាក់បញ្ញើ បានកើនឡើងដល់ ៣ លាន និង ៦,៨ លានគណនី រៀងគ្នា ដែលបានឆ្លុះបញ្ចាំងពីកំណើនជំនឿទុកចិត្តរបស់វិនិយោគិននិងប្រជាពលរដ្ឋមកលើប្រព័ន្ធធនាគារនៅកម្ពុជា។

ក្នុងឱកាសនៃពិធីនេះដែរ ក៏មានការធ្វើបទឧទ្ទេសនាមអំពីប្រវត្តិប្រាក់រៀលដោយ ឯកឧត្តម ជា ចាន់តូ ទេសាភិបាលធនាគារជាតិនៃកម្ពុជា, ការប្រកាសផ្សព្វផ្សាយនូវសៀវភៅស្តីពី "ការកសាងវិស័យហិរញ្ញវត្ថុប្រកបដោយបរិយាប័ន្ន" និងវេទិកាពិភាក្សាស្តីពី "បរិយាប័ន្នហិរញ្ញវត្ថុនៅកម្ពុជា" ដោយមានវាគ្មិនចូលរួមជាថ្នាក់ដឹកនាំធនាគារជាតិនៃកម្ពុជា សមាគមធនាគារនៅកម្ពុជា សមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា និងអ្នកផ្តល់សេវាទូទាត់។

ក្រៅពីនេះ ធនាគារជាតិនៃកម្ពុជាក៏បានចុះអនុស្សរណៈយោគយល់ជាមួយធនាគារ Malayan Banking Berhad ម៉ាឡេស៊ី និងធនាគារមេយប៊ែង (ខេមបូឌា) ដើម្បីសិក្សាលើលទ្ធភាពទូទាត់ឆ្លងដែនតាមរយៈប្រព័ន្ធបាគង។

ពិធីនេះបានប្រព្រឹត្តទៅប្រកបដោយភាពជោគជ័យ និងសេចក្តីសោមនស្សរីករាយ ជាមួយនិងការចងចាំនូវព្រឹត្តិការណ៍ប្រវត្តិសាស្ត្រនៃការបង្កើតធនាគារជាតិនៃកម្ពុជាឡើងវិញ។

**សូមទំនាក់ទំនង៖**
ធនាគារជាតិនៃកម្ពុជា
នាយកដ្ឋានស្រាវជ្រាវសេដ្ឋកិច្ចនិងសហប្រតិបត្តិការអន្តរជាតិ
ទូរស័ព្ទ៖ ០២៣ ៩៩០ ១៩៦
អ៊ីម៉ែល៖ nbccommunication@nbc.org.kh